ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 20-Aug-2015, 15:58
CMS/CFO: Sann Rada

អង្គជំនុំជម្រះតុលាការកំពូល
Supreme Court Chamber
Chambre de la Cour supreme

សំណុំរឿងលេខ: ០០២/១៩-កញ្ញា-២០០៧/អ.វ.ត.ក/អ.ជ.ត.ក
Case File/Dossier N°. 002/19-09-2007/ECCC/SC

| | |
|---|---|
| **នៅចំពោះមុខ៖** | **ចៅក្រម ម៉ុង មុន្នីចរិយា, ចៅក្រមចាត់តាំង** |
| | **ចៅក្រម Chandra Nihal JAYASINGHE, ចៅក្រមចាត់តាំង** |
| **កាលបរិច្ឆេទឯកសារ៖** | **ថ្ងៃទី ២០ ខែ សីហា ឆ្នាំ ២០១៥** |
| **ភាសាដើម៖** | **ខ្មែរ/អង់គ្លេស** |
| **ចំណាត់ថ្នាក់ឯកសារ៖** | **សាធារណៈ:** |

# សេចក្ដីសម្រេចបណ្ដោះអាសន្នលើកទីបីស្ដីពីកិច្ចស៊ើបសួរបន្ថែម

**<u>សហព្រះរាជអាជ្ញា</u>**

ជា លាង
Nicholas KOUMJIAN

**<u>ជនជាប់ចោទ</u>**

ខៀវ សំផន
នួន ជា

**<u>សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី</u>**

ពេជ អង្គ
Marie GUIRAUD

**<u>សហមេធាវីជនជាប់ចោទ នួន ជា</u>**

សុន អរុណ
Victor KOPPE

**<u>សហមេធាវីជនជាប់ចោទ ខៀវ សំផន</u>**

គង់ សំអុន
Anta GUISSÉ
Arthur VERCKEN

**យើង ចៅក្រម ម៉ុង មុន្នីចរិយា និងចៅក្រម Chandra Nihal JAYASINGHE** ជាចៅក្រមចាត់តាំងរបស់អង្គជំនុំជម្រះតុលាការកំពូលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យនៅចន្លោះពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩ ("**អង្គជំនុំជម្រះតុលាការកំពូល**" និង"**អ.វ.ត.ក**"),

**ត្រូវបានចាត់តាំង** ដោយអនុលោមតាម"សេចក្តីសម្រេចបណ្តោះអាសន្នលើផ្នែកខ្លះនៃសំណើទីមួយរបស់ នួន ជា សុំឱ្យទទួល និងពិចារណាលើភស្តុតាងបន្ថែមនៅក្នុងកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង០០២/០១" ("សេចក្តីសម្រេចចាត់តាំង"),[1] នៅក្នុងនោះ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចផ្តួចផ្តើមកិច្ចស៊ើបសួរបន្ថែម ដោយអនុលោមតាមវិធាន ៩៣ នៃវិធានផ្ទៃក្នុង ("កិច្ចស៊ើបសួរបន្ថែម")[2],

**រំលឹក**ថា គោលបំណងសំខាន់នៃកិច្ចស៊ើបសួរបន្ថែម គឺដើម្បីធ្វើការទំនាក់ទំនងដោយផ្ទាល់រវាងលោក Robert Thomas Fitzgibbon LEMKIN ("Robert LEMKIN") និង ថេត សម្បត្តិ ដើម្បីវាយតម្លៃលើបញ្ហាថាតើ ឈុតខ្សែវីដេអូដែលពួកគាត់មានក្នុងដៃនោះ អាចទទួលបានក្នុងពេលវេលាសមស្រប ដែរ ឬយ៉ាងណា និងដើម្បីបញ្ជាក់ ថាតើ មានព័ត៌មានជាក់លាក់អ្វីខ្លះ ដែលអាចទទួលបាននៅក្នុងឈុតខ្សែវីដេអូនោះ[3],

**រំលឹក**ថា ប្រវត្តិនីតិវិធីនៃកិច្ចស៊ើបសួរបន្ថែម ដូចបានរៀបរាប់នៅក្នុង "សេចក្តីសម្រេចស្នើឱ្យដាក់សារណាស្តីពីកិច្ចស៊ើបសួរបន្ថែម" ("សេចក្តីសម្រេចស្នើឱ្យដាក់សារណា")[4] និងជាពិសេស ថា ថេត សម្បត្តិ ពុំបានយល់ព្រម ដោយសារ*ក្នុងចំណោមនោះ*បញ្ហាសុវត្ថិដល់ខ្លួនគាត់ សាច់ញាតិ និងអតីតបុគ្គលិករបស់គាត់ ទៅនឹងការចេញនូវឈុតខ្សែវីដេអូ ឬប្រតិចារិកណាមួយដែលបានមកពីកិច្ចសម្ភាសន៍ដែលធ្វើជាមួយរូបគាត់ ចំណែកឯលោក Robert LEMKIN បានផ្តល់កំណត់ហេតុរបស់ខ្លួន ពាក់ព័ន្ធនឹងកិច្ចសម្ភាសន៍ជាមួយនឹង

---

[1] ថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១៥ កថាខណ្ឌ ២៥ ដល់ ២៦។

[2] វិធានផ្ទៃក្នុងរបស់ អ.វ.ត.ក (វិ.លើកទី ៩) ថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០១៥ ("វិធានផ្ទៃក្នុង")។

[3] សេចក្តីសម្រេចចាត់តាំង កថាខណ្ឌ ២១ ដល់ ២៦។

[4] ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារលេខ F2/4/3/3 ទំព័រ ២ ដល់ ៣។

បុគ្គលទាំងបួនរូបនោះរួចហើយ ("កំណត់ហេតុ" និង"បុគ្គលទាំងបួនរូប")[5] "ពាក់ព័ន្ធនឹងតួនាទី និងរបៀបវារៈផ្ទៃកនយោបាយជាទូទៅរបស់ រស់ ញឹម"[6],

**រំលឹកថា** អង្គជំនុំជម្រះតុលាការកំពូលបានផ្តល់ឱកាសដល់ភាគីក្នុងការបង្ហាញពីបញ្ហាដូចតទៅ៖ "(១) ថាតើ កំណត់ហេតុនេះ គប្បីត្រូវបានទទួលយកជាភស្តុតាង ដែរ ឬយ៉ាងណា, (២) ថាតើ មានចំណាត់ការណាខ្លះបន្ថែមទៀត ដែលចៅក្រមចាត់តាំង ឬអង្គជំនុំជម្រះ គប្បីធ្វើឡើង ទាក់ទងនឹងព័ត៌មានដែលបានមកពីកិច្ចស៊ើបសួរបន្ថែមនោះ"[7],

**កត់សម្គាល់ឃើញថា** សេចក្តីសង្កេតរបស់ភាគីដែលបានធ្វើឡើងជាការឆ្លើយតបទៅនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលស្នើឱ្យដាក់សារណា[8] និង ជាពិសេស ថា នួន ជា និង ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះ ឬចៅក្រមចាត់តាំង គប្បី *ក្នុងចំណោមនោះ* (១) ទទួលយកកំណត់ហេតុនេះធ្វើជាភស្តុតាង[9] (២) កោះហៅលោក Robert LEMKIN និងលោក ថេត សម្បត្តិ មកផ្តល់សក្ខីកម្ម[10], (៣) ស្វែងរកព័ត៌មានបន្ថែមទាក់ទងនឹងបុគ្គលទាំងបួនរូបនោះ ដូចជា សៀវភៅកំណត់ហេតុនៃកិច្ចសម្ភាសន៍របស់ពួកគាត់ និងប្រតិចារិក ឬអត្ថបទចំនួន ១០.០០០ ពាក្យរបស់លោក Robert LEMKIN ដែលត្រូវបានប្រកាស ដែលបានដកស្រង់នៅក្នុងកំណត់ហេតុរបស់គាត់[11] និង (៤) ដើម្បីដោះស្រាយលើ

---

[5] ឧបសម្ព័ន្ធ-កំណត់ហេតុរបស់លោក Robert Lemkin ស្តីពីរបៀបវារៈផ្ទៃកនយោបាយរបស់ រស់ ញឹម (សម្ងាត់) ថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ ២០១៥ ឯកសារលេខ F2/4/3/3.1។

[6] កំណត់ហេតុនៃកិច្ចសម្ភាសន៍សាក្សីជាលាយលក្ខណ៍អក្សរ–Robert T.F. Lemkin ថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារលេខ F2/4/3/1 កថាខណ្ឌ ច.៣៥។

[7] សេចក្តីសម្រេចស្នើឱ្យដាក់សារណាទំព័រ ៣។

[8] ការឆ្លើយតបរបស់ នួន ជា ទៅនឹងសំណួរស្តីពីកិច្ចស៊ើបសួរបន្ថែមរបស់អង្គជំនុំជម្រះតុលាការកំពូលទៅលើឈុតខ្សែវីដេអូដែលមានក្នុងដៃរបស់ផលិតករ គឺលោក Rob Lemkin និង ថេត សម្បត្តិ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០១៥ ឯកសារ F2/4/3/3/1 ("សារណារបស់ នួន ជា")។ សេចក្តីសង្កេតរបស់មេធាវីការពារក្តី ខៀវ សំផន ពាក់ព័ន្ធនឹងការបង្គាប់ឱ្យស្វែងរកព័ត៌មានបន្ថែម ថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០១៥ ឯកសារលេខ F2/4/3/3/2 ("សារណារបស់ ខៀវ សំផន")។ សារណាតបរបស់សហព្រះរាជអាជ្ញាទៅនឹងការឆ្លើយតបរបស់ នួន ជា ទៅនឹងសំណួរស្តីពីកិច្ចស៊ើបសួរបន្ថែមរបស់អង្គជំនុំជម្រះតុលាការកំពូល ទៅលើឈុតខ្សែវីដេអូដែលមានក្នុងដៃរបស់ផលិតករ គឺលោក Rob Lemkin និង ថេត សម្បត្តិ ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៥ ឯកសារលេខ F2/4/3/3/3 ("សារណារបស់សហព្រះរាជអាជ្ញា")។

[9] សារណារបស់ នួន ជា កថាខណ្ឌ ៣ ដល់ ៨។ សារណារបស់ ខៀវ សំផន កថាខណ្ឌ ៦។

[10] សារណារបស់ នួន ជា កថាខណ្ឌ ៩។ សារណារបស់ ខៀវ សំផន កថាខណ្ឌ ៧ និង១៣។

[11] សារណារបស់ នួន ជា កថាខណ្ឌ ៩។ សារណារបស់ ខៀវ សំផន កថាខណ្ឌ ១២។

បញ្ហាសុវត្ថិភាពផ្ទាល់ខ្លួនណាមួយនោះ ផ្តល់ព័ត៌មានឱ្យបានគ្រប់គ្រាន់ដល់បុគ្គលដែលចាប់អារម្មណ៍ទាំងអស់អំពីវិធានការការពារជាច្រើន និងប្រើប្រាស់ឱ្យបានសមស្របនូវវិធានការទាំងនេះដែលមាន នៅ អ.វ.ត.ក[12] ចំណែកឯសហព្រះរាជអាជ្ញា បានអះអាងថា ពុំចាំបាច់ត្រូវការធ្វើចំណាត់ការបន្ថែម ហើយថា សំណើដែលសុំឱ្យទទួលយកកំណត់ហេតុនេះ មកធ្វើជាភស្តុតាង គប្បីត្រូវបានបដិសេធចោល[13],

**កត់សម្គាល់ឃើញថា** អត្តសញ្ញាណនៃបុគ្គលពីររូបក្នុងចំណោមអ្នកទាំងបួននេះ រួមទាំងការដកស្រង់នៃកិច្ចសម្ភាសន៍របស់ពួកគាត់ជាមួយនឹង ថេត សម្បត្តិ បានបង្ហាញនៅក្នុងសៀវភៅរបស់ **Gina CHON** និង **ថេត សម្បត្តិ** ចំណងជើងថា *នៅពីក្រោយវាលពិឃាត*[14] ខណៈដែល បុគ្គលម្នាក់ក្នុងចំណោមនោះ បានផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូលជាសាធារណៈ[15] ហេតុនេះហើយ ឃើញថា អត្តសញ្ញាណ និងតួនាទីរបស់ពួកគាត់នៅក្នុងរបបខ្មែរក្រហម ត្រូវបានផ្សព្វផ្សាយជាសាធារណៈរួចហើយ,

**ដោយពិចារណាឃើញថា** ដោយភាពទំនងជាអាចកើតមានយ៉ាងខ្លាំងដែលថា បុគ្គលពីររូបដែលបានបង្ហាញនៅក្នុងកំណត់ហេតុ និងបានបង្ហាញឈ្មោះនៅក្នុងសៀវភៅចំណងជើងថា *នៅពីក្រោយវាលពិឃាត* គឺជាបុគ្គលតែមួយក្នុងចំណោមបុគ្គលដែល នួន ជា បានស្នើសុំផ្តល់សក្ខីកម្មក្នុងកិច្ចនីតិវិធីនៃបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១[16],

**រំលឹកថា** ក្របខណ្ឌច្បាប់នៃ អ.វ.ត.ក ចែងអំពីវិធានការការពារក្នុងការផ្តល់សុវត្ថិភាពដល់ជនរងគ្រោះ សាក្សី សមាជិកគ្រួសារ និងសាច់ញាតិរបស់ពួកគេ ដែលវិសាលភាពនេះបានអនុញ្ញាតឱ្យអង្គជំនុំជម្រះ

[12] សារណារបស់ នួន ជា កថាខណ្ឌ ៩។ សារណារបស់ ខៀវ សំផន កថាខណ្ឌ ៧ ដល់ ១១។

[13] សារណារបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៤១។

[14] សៀវភៅរបស់ Gina Chon និង ថេត សម្បត្តិ ចំណងជើងថា *ពីក្រោយវាលពិឃាត* សារព័ត៌មាននៃសាកលវិទ្យាល័យ Pennsylvania ឆ្នាំ ២០១០ ឯកសារលេខ E3/4202 ទំព័រ ១០៦ ដល់ ១០៧។

[15] អ៊ីម៉ែលជាអេឡិចត្រូនិចផ្ញើពីអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ("WESU") មកកាន់ក្រឡាបញ្ជីនៃអង្គជំនុំជម្រះតុលាការកំពូលចំណងជើងថា "បញ្ជូនត: បច្ចុប្បន្នភាពស្តីពីកំណត់ហេតុសម្ងាត់" ថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១៥ នៅម៉ោង ០១ និង ៥២ ល្ងាច នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល ("អ៊ីម៉ែលថ្ងៃទី ១១ ខែ សីហា ២០១៥") (ការបញ្ជូនអ៊ីម៉ែលថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០១៥ ពីលោក Robert Lemkin ដែលក្នុងអ៊ីម៉ែលគាត់បានសង្កេតថា បុគ្គលដែលបាននិយាយសំដៅ ថាជា"W2"នៅក្នុងកំណត់ហេតុ បានមកផ្តល់ភស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល ខណៈបុគ្គលដែលបានបង្ហាញអត្តសញ្ញាណជា "W1"និង"W3"នៅក្នុងកំណត់ហេតុ ត្រូវបានបង្ហាញឈ្មោះនៅក្នុងសៀវភៅដែលមានចំណងជើងថា *នៅពីក្រោយវាលពិឃាត*)។

[16] សំណើទីប្រាំរបស់ នួន ជា សុំពិចារណា និងទទួលយកភស្តុតាងបន្ថែមទាក់ទងទៅនឹងបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមក្នុងសំណុំរឿង ០០២/០១(សម្ងាត់បំផុត) ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារលេខ F2/7 កថាខណ្ឌ ៤២ ដល់ ៤៦។

ដោះស្រាយយ៉ាងមានប្រសិទ្ធិភាពចំពោះក្ដីបារម្ភណាមួយ ទាក់ទងនឹងបញ្ហានេះ និងធានាបាននូវអនាមិកភាពយ៉ាងសមស្រប ជាឧទាហរណ៍តាមរយៈការបង្កើតជាឈ្មោះក្លែងក្លាយ ការធ្វើកំណត់ត្រាលើចម្លើយដោយពុំមានដាក់អត្តសញ្ញាណរបស់ម្ចាស់ចម្លើយពេលដាក់ចូលក្នុងសំណុំរឿង ការបំផ្លែងសំលេងដើម និងបិទបាំងភិនភាគរបស់បុគ្គល ការបើកសវនាការ *ជាសម្ងាត់* ការបង្គាប់ឱ្យមានការការពារផ្នែករូបរាងកាយរបស់បុគ្គល និងការផ្ដល់សុវត្ថិភាពនៃលំនៅដ្ឋាននៅក្នុងប្រទេស ឬនៅក្រៅប្រទេសនៃព្រះរាជាណាចក្រកម្ពុជា និងការកោសលុបចេញនូវព័ត៌មាន ដែលអាចនាំឱ្យមានការបង្ហាញនូវអត្តសញ្ញាណនៃបុគ្គលដែលត្រូវបានការពារ ឬទីលំនៅរបស់ខ្លួន[17]។

**ដោយពិចារណាឃើញ**ថា អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលអាចបង្គាប់ដោយមានការពិគ្រោះពិភាក្សាជាមួយ អង្គភាពគាំពារសាក្សី និងអ្នកជំនាញ នូវវិធានការណាមួយ ដែលខ្លួនយល់ឃើញថាចាំបាច់ និងសមស្របដើម្បីដោះស្រាយបញ្ហាសុវត្ថិភាព និងសន្តិសុខដែលសាក្សីបានស្នើ និងថា ការវាយតម្លៃលើបញ្ហាផ្នែកសន្តិសុខ លើភាពសមាមាត្រនៃវិធានការការពារជាមួយនឹងហានិភ័យ និងលើទម្រង់បែបបទក្នុងការធានាបាននូវការគោរពសិទ្ធិរបស់ជនជាប់ចោទ ក្នុងការទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ នៅក្នុងបរិបទនៃការជំនុំជម្រះរឿងក្ដីព្រហ្មទណ្ឌ គឺជាកិច្ចសហប្រតិបត្តិការមួយដែលមានចែងយ៉ាងច្បាស់លាស់ក្នុងកិច្ចដំណើរការនីតិវិធីដ៏ស្មុគស្មាញ ដែលស្ថិតនៅក្នុងការទទួលខុសត្រូវ និងជាកាតព្វកិច្ចរបស់ចៅក្រម[18],

**ដោយពិចារណាឃើញ**ថា មានព័ត៌មានបន្ថែម ដែលតម្រូវឱ្យធ្វើការវាយតម្លៃយ៉ាងត្រឹមត្រូវ *ក្នុងចំណោមនោះ* មានដូចជាភាពពាក់ព័ន្ធ ភាពអាចជឿជាក់បាន និងភាពអាចទុកចិត្តបាននៃកំណត់ហេតុ និងសក្ខីកម្មដែលមានសក្ដានុពលរបស់បុគ្គលទាំងបួនរូបនោះ និងថា ការដែលអង្គជំនុំជម្រះ និងភាគីអាចទទួលបានប្រភពព័ត៌មានជាបឋមដែលផ្អែកលើកំណត់ហេតុនេះ គឺជាផលប្រយោជន៍យុត្តិធម៌,

**បញ្ជាក់**ថា ក្ដីបារម្ភណាមួយអំពីបញ្ហាសន្តិសុខ ត្រូវបានពិចារណាដោយយកចិត្តទុកដាក់បំផុត ហើយអង្គជំនុំជម្រះ ដោយមានការជួយសហការពីអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ត្រូវតែស្វែងរកនូវការ

---

[17] វិធាន ២៩ (៤) នៃវិធានផ្ទៃក្នុង។ សេចក្ដីណែនាំអនុវត្តស្ដីពីវិធានការការពារ ថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០០៨ ឯកសារ ECCC/03/2007/Rev.1 ("សេចក្ដីណែនាំអនុវត្តស្ដីពីវិធានការការពារ") មាត្រា ៣។

[18] *សូមមើលឧ.* វិធាន ២៩ នៃវិធានផ្ទៃក្នុង។ សេចក្ដីណែនាំអនុវត្តស្ដីពីវិធានការការពារ មាត្រា ១.៣ ដល់ ១.៤។

យល់ព្រមពីបុគ្គលដែលស្ថិតក្រោមវិធានការការពារនេះ[19] និងថា ជានិច្ចកាល ការចាត់ចំណាត់ថ្នាក់លើសម្ភារៈដែលទទួលបាន ត្រូវតែធ្វើឡើង ដោយពិចារណាទៅលើបញ្ហានៃសន្តិសុខ,

**ដោយពិចារណាឃើញថា** Robert LEMKIN បានអនុវត្តតាមសំណើរបស់ចៅក្រមចាត់តាំងក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរបន្ថែម ហើយថ្មីៗនេះ គាត់បានបញ្ជាក់ពីឆន្ទៈក្នុងការផ្តល់ជូនតុលាការនូវព័ត៌មានបន្ថែមទាក់ទងនឹងបុគ្គលទាំងបួនរូបនោះ[20],

## អាស្រ័យហេតុនេះ

**សម្រេចស្នើឱ្យ** លោក Robert LEMKIN ផ្តល់នូវប្រតិចារិកទាំងអស់ និងសៀវភៅកំណត់ហេតុទាក់ទងនឹងបទសម្ភាសន៍ជាមួយបុគ្គលទាំងបួនរូបនោះ ដល់អង្គភាពគាំពារសាក្សី និងអ្នកជំនាញ ដោយចាត់ទុកជាឯកសារសម្ងាត់បំផុតយ៉ាងយូរត្រឹមថ្ងៃ អាទិត្យ ទី ៣០ ខែ សីហា ឆ្នាំ ២០១៥,

**បង្គាប់** ឱ្យអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ធ្វើការទំនាក់ទំនងជាមួយលោក Robert LEMKIN តាមដែលអាចធ្វើទៅបាន ដោយធ្វើការពិគ្រោះពិភាក្សាជាមួយក្រឡាបញ្ជីនៃអង្គជំនុំជម្រះតុលាការកំពូល ត្រូវបញ្ជាក់ពីវិធីសាស្ត្រក្នុងការប្រុងប្រយ័ត្នទុកជាមុនលើផ្នែកបច្ចេកទេស ដែលចាំបាច់ត្រូវរក្សានូវភាពសម្ងាត់នៃសម្ភារៈនោះ និងធ្វើរបាយការណ៍នូវលទ្ធផលនេះ មកកាន់ចៅក្រមចាត់តាំងយ៉ាងយូរត្រឹមថ្ងៃ ច័ន្ទ ទី ៣១ ខែ សីហា ឆ្នាំ ២០១៥ ដោយត្រូវប្រគល់ជូននូវសម្ភារៈណាមួយដែលអង្គភាពបានទទួល,

**បង្គាប់** ឱ្យអង្គភាពគាំពារសាក្សី និងអ្នកជំនាញ បន្ទាប់ទទួលបាននូវសម្ភារៈដែលមានព័ត៌មានបង្ហាញពីអត្តសញ្ញាណទាក់ទងនឹងបុគ្គលដែលនិយាយសំដៅទៅលើជា "W4" ដើម្បីធ្វើការទំនាក់ទំនងជាមួយបុគ្គលនេះ និងធ្វើការវាយតម្លៃលើគ្រោះថ្នាក់នៃការបង្ហាញនូវអត្តសញ្ញាណរបស់គាត់ ដែលអាចកើតមានដល់អាយុជីវិត ឬសុខភាពរបស់គាត់ ឬសមាជិកក្រុមគ្រួសារ ឬសាច់ញាតិជិតដិតរបស់គាត់ ឬបុគ្គលដទៃទៀតដែលជាប់ពាក់ព័ន្ធទៅនឹងការធ្វើកិច្ចសម្ភាសន៍ និងរាយការណ៍លទ្ធផលនៃការវាយតម្លៃនោះមកជូន ចៅក្រមចាត់តាំងឱ្យបានឆាប់ដែលអាចធ្វើទៅបាន។

---

[19] សេចក្តីណែនាំអនុវត្តស្តីពីវិធានការការពារ មាត្រា ១.៥។

[20] អ៊ីម៉ែលចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១៥ ("ខ្ញុំមានសេចក្តីត្រេកអរ ក្នុងការផ្តល់ជូនដល់តុលាការនូវកំណត់ហេតុរបស់ខ្ញុំ (ជាលាយលក្ខណ៍អក្សរឬដោយផ្ទាល់មាត់) អំពីកំណត់ហេតុរបស់បុគ្គលទាំងបីរូបនេះ ដែលមានឈ្មោះ [W1, W2 និង W3] ដែលខ្ញុំបានកត់ត្រាក្នុងឆ្នាំ ២០០៨ ដល់ ២០០៩។[...]អត្តសញ្ញាណនៃ W4 នៅក្នុងកំណត់ហេតុរបស់ខ្ញុំនៅតែជាអនាមិក ហើយព័ត៌មានលម្អិតណាមួយនៃភស្តុតាងរបស់គាត់ដែលអាចនាំទៅដល់ការបង្ហាញអត្តសញ្ញាណ ចាំបាច់ត្រូវតែរក្សាជាសម្ងាត់")។

សំណុំរឿងលេខៈ ០០២/១៩-កញ្ញា-២០០៧/អ.វ.ត.ក/អ.ជ.ត.ក

ឯកសារលេខ F2/4/3/3/5

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ សីហា ឆ្នាំ ២០១៥

**ចៅក្រមចាត់តាំងនៃអង្គជំនុំជម្រះតុលាការកំពូល**

**Chandra Nihal JAYASINGHE** **ម៉ុង មុន្នីចរិយា**